# បច្ចេកទេសបង្កាត់ពូជស្វាយចន្ទី

## ការជ្រើសរើសពូជដែលមានទិន្នផលខ្ពស់

ភាគច្រើននៃពូជដែលបានរំដោះដោយស្ថានីយ៍ស្រាវជ្រាវគឺមិនមានបញ្ហាអ្វីទេក្នុងការជ្រើសរើសពូជ។ កសិករអាចធ្វើការសង្កេតតាមដាននិងអាចធ្វើការជ្រើសរើសពូជដោយខ្លួនគាត់ដោយផ្ទាល់។ ការជ្រើសរើសគឺត្រូវដាក់ឈ្មោះផ្តល់នូវអត្តសញ្ញាណហើយបន្តធ្វើឱ្យមានចំនួនពូជនេះកើនឡើងច្រើន គួរតែធ្វើលើសរីរាង្គលូតលាស់របស់វាពោលគឺធ្វើតាមរយៈការបំបៅឬ ផ្សាំមែក។ យោងតាមការវិនិច្ឆ័យនេះយើងអាចធ្វើការជ្រើសរើសនៅលើដើមណាដែលបានផ្តល់ទិន្នផលខ្ពស់ និង មានលក្ខណៈដូចខាងក្រោមៈ

-រុក្ខជាតិមានការលូតលាស់លឿន មែកបែកសាខានិងស្រឡះល្អ

-ត្រូវមានកញ្ចុំផ្កាពី ១០ -៣០ កញ្ចុំក្នុង ១ ម៉ែត្រការ៉េ។ ចំនួនកញ្ចុំផ្កាច្រើនគឺមានសក្តានុពលនៃទិន្នផល។

-ផ្កាទ្វេភេទដែលមានចំនួនពី ១០-៣០០។ ចំនួនផ្កាទ្វេភេទច្រើន គឺបានទិន្នផលច្រើន។

-ទម្ងន់គ្រាប់ ជាមធ្យម ៧ ក្រាម ក្នុងមួយគ្រាប់

-រុក្ខជាតិត្រូវចាប់ផ្តើមចេញផ្កា (មករា-កុម្ភៈ) ឬ (កុម្ភៈ-មីនា)ដើម្បីជៀសផុតពីពួក **មូសតែ។** រដូវ ចេញផ្កាមានរយៈពេលខ្លី (១-៣ខែ)។

-ដើមឈើត្រូវតែមានភាពធន់ទ្រាំនឹងការបំផ្លាញសត្វល្អិត និង ជំងឺ

-ភាគរយនៃទិន្នផលគ្រាប់ត្រូវតែច្រើនជាង ២៨ % នៃគ្រាប់ទាំងមូល

-ដើមឈើពេញវ័យល្អ (អាយុ ១៥ឆ្នាំ ឬលើសនេះ) ត្រូវតែផ្តល់ផលពី ១៥-២៥ គ.ក្រ។

-ចំពោះដើមដែលដាំនៅដាច់តែឯងផ្តល់ផលប្រហែលជាក្នុងមួយដើម ផ្តល់ផលបាន ៥០-៦០ គ.ក្រ។

## ការបន្តពូជតាមសរីរាង្គលូតលាស់

ភាគច្រើននៃចំការស្វាយចន្ទីចាស់ៗ ត្រូវបានបង្កើតឡើងដោយការដាំកូនដែលបណ្តុះពីគ្រាប់ ។ រុក្ខជាតិដែលបានមកមិនមានលក្ខណៈជាឯកសណ្ឋានភាព ដូច្នេះដើម្បីទទួលបានជោគជ័យក្នុងបញ្ហានេះ គេត្រូវធ្វើការបំបៅ ដោយធ្វើការជ្រើសរើសមែកពូជដែលមានគ្រាប់ធំហើយទិន្នផលជាមធ្យម ច្រើន ជាង ១០ គ.ក្រ ក្នុងមួយដើម ក្នុងមួយឆ្នាំ អាចជ្រើសរើសសម្រាប់ការបង្កើនចំនួនស្វាយចន្ទីនេះ។

វិធីសាស្ត្រផ្សាំ និងបំបៅសរីរាង្គខ្ចី គឺជាវិធីសាស្ត្រពីរដែលអាចធ្វើបានសម្រាប់បង្កើននូវចំនួនកូនរុក្ខជាតិដោយប្រើប្រាស់សរីរាង្គលូតលាស់។ ចំណែកការផ្សាំ និង បំបៅ អាចធ្វើបានដោយកសិករធម្មតា។ វិធីសាស្ត្រទាំងពីរនេះ គឺមានការចំណាយច្រើនជាង ការដាំដោយគ្រាប់ ហើយត្រូវមានការអនុវត្តន៍ និង ការគ្រប់គ្រងរោងបណ្តុះឱ្យបានល្អ។

### ក. វិធីសាស្ត្រសាកមែក

ជ្រើសរើសមែកពូជណាដែលពេញវ័យល្អមានទំហំប្រហែលម្រាមដៃ ត្រូវមានប្រវែង ៣០-

៤០ ស.ម ពីខាងចុងនៃមែក ។ មែកនោះត្រូវចិតយកសំបកឈើ ដោយក្រឡឹងជុំវិញមែកប្រវែង ២,៥ ស.មយកវាចេញដោយថ្នមៗបន្ទាប់មកកោសរំអិលវាចេញ ។ បំណែកស្រកីដូងម៉ត់ ឬអាចម៍រណាដែលផ្សើមរួចដាក់ឱ្យចំមុខដែលចៀវសំបកដែលមានទទឹង ១០ ស.ម ដោយប្រើបន្ទះប្លាស្ទិក (គេប្រើនៅរដូវប្រាំង) ឬ ក្រណាត់កូតុងស្តើងៗ ហើយផ្សើមកន្លែងចងនោះ ។

ឫសនឹងលេចចេញក្នុងកំឡុងពេលពី ៤៥-៦០ ថ្ងៃ ក្រោយពេលផ្សាំ។ ពេលឫសដុះចេញ ដកប្លាស្ទិកចេញ ហើយកាត់ភាគខ្លះនៅគល់ ។ ក្រោយរយៈពេលមួយអាទិត្យ ប្រសិនបើស្លឹកដែលសាកនោះ នៅមានពណ៌បៃតង យើងអាចកាត់មែកនោះចេញមកត្រៀមដាំបាន។ ដើមដែលដុះឫសចេញមកនេះរក្សាទុកនៅក្នុងរោងបណ្តុះដោយមានម្លប់ ៥០ភាគរយ។ ការដាំដុះដោយសាករបៀបនេះ គប្បីថែទាំឱ្យបានត្រឹមត្រូវល្អ ជៀសវាងការបំផ្លាញពីកត្តាផ្សេងៗដល់ឫសខ្ចី ដែលទើបតែដុះថ្មី។


ជ្រើសរើសមែកល្អ



ចិតសំបកខាងក្រៅមែក


ស្រកីដូងរុំកន្លែងចិត


ចងប្លាស្ទិករុំភ្ជិត


បាវក្រចៅរុំភ្ជិត



ចិតមែកបន្តិចម្តងៗរហូតដល់ដើមចេញឫសមាំទាំ


កាត់ទុកដាំ

## ខ.ការតត្រួយ(នៅលើដើមទំរដែលមានអាយុពី ៤៥ ថ្ងៃ ទៅ ៦០ ថ្ងៃ)

បច្ចេកទេសត្រឹមត្រូវនៃការបំបៅសិរាង្គខ្ចីគឺមានលំអិតដូចខាងក្រោមៈ

-កូនចន្ទីមានអាយុ ៤៥-៦០ ថ្ងៃ ដែលបានបណ្តុះនៅក្នុងថង់ប្លាស្ទិក (បណ្តោយ ២៥ ស.ម x ១៥ ស.ម កំរាស់ 0,0៣ ស.ម ) ប្រើប្រាស់ជាគល់ទំរ ។

-បន្ទាប់ពីការជ្រើសរើសពន្លកពូជដែលដុះលូតលាស់ថ្មីៗ(គ្មានផ្កាមានអាយុពី៣-៥ខែ ) ត្រូវយកហើយត្រូវធ្វើការចៀរសំអាតលើដើមមេ ដោយកាត់តួស្លឹកចេញ ទុកតែទងស្លឹកជាប់នឹងដើម។ បន្ទាប់ពី អាយុបាន១០-១៥ថ្ងៃ ពន្លកដែលបានសំអាតត្រូវបាន គេប្រមូលយកកំណាត់ភ្នែកទៅប្រើសម្រាប់បំបៅ។

-គល់ទំរត្រូវបានរៀបចំដោយធ្វើការកាត់ចោលស្លឹកទាំងអស់ ដោយទុកតែពីរគូរនៅស្លឹកខាងក្រោមបង្អស់ ។ ការលូតលាស់ផ្នែកចុង(ផ្នែកសិរាង្គខ្ចី) ដែលមានកំពស់ចាប់ពីក្រោមទៅលើ ១៥ ស.ម ត្រូវច្រៀកដើមអោយមានប្រវែង ៥-៦ ស.ម។

-ត្រួយពូជដែលបំបែកចេញពីដើមមេនោះ ត្រូវយកទៅស៊កភ្ជាប់ចូលទៅក្នុងសំបកឈើដែលយើងបានកាត់ឆូតខាងលើប្រវែង ៥-៦ ស.ម ។

-ស៊ៀតត្រួយពូជចូលទៅក្នុងស្នាមឆូតដែលស្ថិតនៅលើគល់ទំរដោយប្រុងប្រយ័ត្នគឺលៃយ៉ាងណាឱ្យស្រទាប់រំអិល (ជាមប៊ិម)របស់ដើមទំរ និងត្រួយពូជត្រួតស៊ីគ្នា។

-កន្លែងបំបៅត្រូវបានចងភ្ជាប់ដោយបង់រុំ(ទំហំ ១.៥ ស.ម ប្រវែង ៣0 ស.ម និង កំរាស់ 0,0១ ស.ម )។

-ថង់គ្រប(ទំហំ ២0 ស.ម x ៤ ស.ម និង កំរាស់ 0,0២ ស.ម) គឺគ្របទៅលើរុក្ខជាតិដែលបានបំបៅរួចដើម្បីការពារពន្លកនេះមិនអោយស្ងួត ។

-ការតត្រួយគួរប្រព្រឹត្តទៅក្រោមម្លប់ក្នុងរោងបណ្តុះ បន្ទាប់មកយកដើមដែលតត្រួយនោះទៅទុកនៅក្នុងម្លប់ប្រហែលជា ១៥ ថ្ងៃ ហើយផ្ទេរទៅកន្លែងដែលមានខ្យល់អាកាសគ្រប់គ្រាន់។

-រាល់មែកបំបៅត្រូវមើលការថែទាំនៅថ្នាល រហូតដល់រដូវដាំដុះលើកក្រោយ ។ មែកបំបៅរួចនឹងត្រូវធ្វើការដាំដុះបន្ទាប់ពីបំបៅបានពី ៥-៦ ខែ ដាច់ខាត។



មែកភ្នែកសម្រាប់ជ្រើសរើស



ត្រួយសម្រាប់បំបៅ



ដើមទំរ



សំអាតធាងស្លឹក



ចិតមែកពូជជាមុខទួរណឺវីស



ច្រៀកដើមសម្រាប់តត្រួយ



ត្រួយសម្រាប់សៀត



ស៊កត្រួយទៅនឹងដើមទំរ



រុំភ្ជាប់





ចងត្រួយជាមួយដើមទំរ



យកថង់ប្លាស្ទិកគ្របពីលើ

**បច្ចេកទេសតត្រួយលើដើមចាស់**

ការតត្រួយដើមចាស់ គឺជាបច្ចេកទេសដែលគេអនុវត្តទៅលើដើមចាស់ដែលមិនផ្តល់ផល ឬ ផ្តល់ផលទាប ។ ដើមដែលមានទិន្នផលទាប ដែលមានអាយុ ៥-២០ ឆ្នាំអាចធ្វើអោយមានទិន្នផលខ្ពស់វិញបានតាមរយៈការបំបៅដើម ។ គេអនុវត្តន៍ការបំបៅដើមចាស់ដោយ ៖

- ជាដំបូងត្រូវកាត់ដើមចាស់ដែលដោយទុកកំពស់ 0,៧៥ - ១ម ពីដី ដោយប្រយ័ត្នជៀសវាងកុំអោយដើមវាបែកសាច់ឈើ បើប្រើរណាអារដើមជាការល្អអនុវត្តនៅខែមិនា-មេសា
- រដូវដែលល្អសម្រាប់តត្រួយនៃដើមចាស់ត្រូវធ្វើនៅខែ ឧសភា-កញ្ញា
- ពន្លកនៃបំពង់ថ្មីនឹងចេញ ៣០-៤៥ ថ្ងៃ បន្ទាប់ពីការកាត់ ផ្អែកលើដើមចោល ។ យើងទុក ៦-៧ នៃបំពង់លាស់ថ្មីក្នុងមួយដើម សម្រាប់ធ្វើការតត្រួយ ។
- រីឯវិធីតត្រួយដូចគ្នានឹងវិធីតត្រួយលើដើមទំរដែរ ។



ការកាត់បំពង់ដែលទើបតែលាស់ថ្មី



ការតត្រួយជាមួយបំពង់ដែលល្អ



ការតត្រួយលើបំពង់ផ្សេងទៀតតែលើដើមតែមួយ



ការខ្ចប់ក្រដាសការពារសំណើមពេលធ្វើការតត្រួយរួច

## តត្រួយលើដើមចាស់